**សកម្មភាព** ៖ **ល្បែងផាត់ពណ៌ជាមួយគ្រឿងទេស**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង និងការបញ្ចេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

**(សិក្សាសង្គម)** ផាត់ពណ៌ដើម្បីបង្កើតជារូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលគេបានបង្កើត។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?" ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសរលោង សំឡីត្បារត្រចៀក ទឹក គ្រឿងទេសផ្សេងៗ ឬ ទឹកពណ៌ (ឧ.ម្សៅរមៀត ប្រភេទផ្កា ឬ បន្លែមួយចំនួនអាចមានពណ៌ ផ្លែការី និងរបស់ធម្មជាតិជាដើម)ចាន និងកូនស្លាបព្រាដែលអាចប្រើសម្រាប់លាយពណ៌។

**ការរៀបចំ** ៖ រមៀត បន្លែ និងគ្រឿងទេសផ្សេងៗ អ្នកនឹងទទួលបានបទពិសោធន៍ដែលអ្នកចង់បាន។

**សេចក្ដីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងផាត់ពណ៌ជាមួយគ្រឿងទេស**ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងថា៖ តើស្បង់ចីវរបស់ព្រះសង្ឃមានពណ៌អ្វីខ្លះ? ស្បង់ចីវររបស់ទ្រង់គឺមានពណ៌ស្លាទុំ តើហេតុអ្វីបានជាព្រះសង្ឃឃ្លុំស្បង់ចីវរពណ៌ហ្នឹង? ពីព្រោះព្រះសង្ឃឃ្លុំតាមពណ៌ធម្មជាតិ ។
3. ប្រាប់ក្មេងៗ៖ រមៀត ពណ៌ខ្លឹមខ្នុរ..ដែលព្រះសង្ឃគ្រប់អង្គងាយស្រួលក្នុងការស្វែងរកពណ៌ ។
4. បង្ហាញឈ្មោះគ្រឿងទេសដែលអ្នកចង់ប្រាប់ដល់ក្មេងៗ ។

5. សួរក្មេងៗ៖ តើពណ៌ណាដែលកូនៗអាចបង្កើតបាន?
6. លាយទឹកពណ៌បង្ហាញឱ្យក្មេងៗទាំងអស់មើល។
7. ដូច្នេះក្មេងៗអាចមើលឃើញថាគ្រឿងទេសនានាអាចចេញពណ៌អ្វីខ្លះ។
8. ចែកក្រដាសស សំឡីត្បារត្រចៀក និងទឹកពណ៌ ទៅកាន់ក្មេងៗ។
9. ចូរសួរក្មេងៗឱ្យប្រើសំឡីត្បារត្រចៀក ដើម្បីផាត់ពណ៌រូបភាព។ ដូចជាការផាត់ពណ៌អញ្ចឹងដែរ ពួកគេគួរតែប្រាកដថាត្រូវដាក់សំឡីទាំងអស់ហ្នឹងឱ្យត្រូវទៅនឹងចានតាមពណ៌នីមួយៗដើម្បីជៀសវាងកុំឱ្យមានពណ៌លាយគ្នា។